ថ្ងៃទី៨ខែមិនាឆ្នាំ២០០៨
ទីក្រុងហ្វិឡាដែលភ្យា សហរដ្ឋអាមេរិក
អបអរសាទរទិវានារីអន្តរជាតិ

ជារៀងរាល់ឆ្នាំនាថ្ងៃទី០៨ខែមិនា ស្ត្រីរាប់ពាន់ម៉ឺនសែននាក់បានចូលរួមក្នុងទិវានារីអន្តរជាតិ។ ទិវានារីអន្តរជាតិបានកើតឡើងនៅជុំវិញសកលក្នុងបំណងលើកតម្លៃស្ត្រីការពារសិទ្ធស្ត្រីនិងធ្វើការអបអរសាទរចំពោះស្ត្រីដែលបានចូលរួមយ៉ាងសកម្មដើម្បីសន្តិភាពសេរីភាពសុភមង្គលប្រចាំគ្រួសារ សង្គមនិងប្រទេសរបស់ផងគេ។
នាដើមឆ្នាំ២០០៧ជាទិវាប្រវត្តិសា ស្ត្រមួយរបស់ស្ត្រីខ្មែរក្រោមដែលបានចូលរួមជាលើកទី១ដើម្បីបកស្រាយនូវទុក្ខសោកទារុណកម្មការរើសអើងបំបិតសិទ្ធសេរីភាពគ្រប់បែបយ៉ាងពីរដ្ឋាភិបាលយួនកុម្មុយនិស្តនៅអង្គការសហប្រជាជាតិនាបូរីញូវយ៉កសហរដ្ឋអាមេរិក។
ទោះប្បីជារដ្ឋាភិបាលកុម្មុយនិស្តយួនបានចុះហត្ថលេខាទទួលយកច្បាប់សិទ្ធមនុស្សមិនរើសអើង ស្ត្រីភេទនៅថ្ងៃទី២៩ខែកក្កដាឆ្នាំ១៩៨០ក៏ដោយរដ្ឋាភិបាលកុម្មុនិស្តនេះមិនដែលបានគោរពនិងអនុវត្តម្តងណាឡើយ។
ស្ត្រីខ្មែរក្រោមត្រូវបានទទួលរងនូវការរំលោភតាមយុទ្ធវិធីធ្វើឲ្យអវិជ្ជាក្រីក្រទាល់ច្រកនិងមិនស្គាល់ទាល់តែសោះអ្វីទៅហៅថាទិវានារីអន្តរជាតិឬសិទ្ធស្ត្រីនោះ។ ស្ត្រីខ្មែរក្រោម៩៩ភាគរយគ្មានការងារធ្វើនិងគ្មានវិជ្ជាជំនាញដើម្បីរករបរចិញ្ចឹមជីវិតក្រោយពីដីស្រែរបស់ខ្លួនត្រូវបានរដ្ឋកុម្មុនិស្តរិបអូសយក។ស្ត្រីខ្មែរ៩៥ភាគរយមិនចេះអក្សរសា ស្ត្រខ្មែរសំរាប់សរសេរឬអានក៏គ្មានមិនតែប៉ុណ្ណោះគ្មានភពវាសនាបានទទួលការសិក្សាថ្នាក់មធ្យមសិក្សានិងបានទទួលនូវការឧបត្ថម្ភណាមួយឬគំរោងណាមួយដើម្បីបានមកសិក្សានៅប្រទេសអភិវឌ្ឍដូចស្ត្រីវៀតណាម។ ស្ត្រីខ្មែរក្រោមបានធ្លាក់ចូលក្នុងការបោកបញ្ឆោតជួញដូរផ្លូវភេទនិងជាទាសករនៅបរទេសលដោយសារភាពអវិជ្ជាក្រីក្រនេះ។
នាថ្ងៃទី២៦ខែកុម្ភៈឆ្នាំ២០០៨ ស្ត្រីខ្មែរក្រោមនៅស្រុកសទិនបៀ្យង ខេត្តមាត់ជ្រូកត្រូវបានរដ្ឋអំណាចកុម្មុយនិស្តយួនវាយធ្វើបាបដោយប្រើដំបងឆក់ខ្សែភ្លើងនិងរងរបួសទាំង២៩នាក់ក្នុងនោះមាន៩នាក់របួសធ្ងន់និង២នាក់រហូតដល់ចូលព្យាបាលនៅមន្ទីពេទ្យ។ប្រិត្តិការជ៍ល្ងិងដូច

តទឹកភ្នែកក្លាយជាឈាមត្រូវរងការគំរាមចាប់ចងដាក់គុកច្រវាក់ដូចមានកើតឡើងកាលចុងឆ្នាំ២០០៧ទៅរូបលោកស្រី**នាងយ៉េ**ជាដើម។

ពេលថ្មីៗនេះនាថ្ងៃទី២៤ខែកុម្ភៈឆ្នាំ២០០៨នៅខេត្តឃ្លាំងពួកប្រជារាស្ត្រយួនដោយមានការគាំទ្រពីរដ្ឋអំណាចផងនោះបានលើកគ្នាមកដុះផ្ទះលោកស្រី**លីធីហឿង**ដោយមូលហេតុតវ៉ាយកមកវិញនូវដីស្រែដែលរដ្ឋអំណាចកុម្មុនិស្តយួនរិបអូសយកឲ្យប្រជាជនយួន។

ប្រិត្តិការរំលោភសិទ្ធស្ត្រីខ្មែរក្រោមកើតមានឡើងជារាងរាល់ថ្ងៃដោយរដ្ឋអំណាចកុម្មុនិស្តយួនដែលផ្ទុយស្រឡះនូវច្បាប់ការពារស្ត្រីនិងទិវានារីអន្តរជាតិ។

ដើម្បីបញ្ឈប់នូវអំពើរំលោភសិទ្ធស្ត្រីខ្មែរក្រោមនិងអបអរបុណ្យទិវានារីអន្តរជាតិយើងខ្ញុំសូមអំពាវនាវដល់ស្ត្រីខ្មែរនិងខ្មែរក្រោមទាំងអស់ជាពិសេសនៅក្នុងស្រុកមេត្តាក្រោកឈរឡើងដើម្បីទាមទារឲ្យរដ្ឋាភិបាលកុម្មុនិស្តយួនគោរពនូវរាល់ច្បាប់សិទ្ធនារី។

តាំងនាមសហព័ន្ធខ្មែរកម្ពុជាក្រោមយើងខ្ញុំសូមប្រសិទ្ធពរដល់ស្ត្រីក្នុងពិភពលោកនិងស្ត្រីខ្មែរបានជួបតែសេចក្តីសុខនិងពុទ្ធពរទាំង៥ប្រការគឺអាយុ វណ្ណៈសុខៈ ពលៈនិងបដិភាណៈកុំបីឃ្លាងឃ្លាតឡើយ។

ដោយគោរពរាប់អានអំពីនាងខ្ញុំ

សឺន ធី និត
ប្រធានស្ត្រីខ្មែរក្រោម